# តំបន់សិក្សាទី ២ គណៈកម្មការរៀបចំផែនការ

## ការកំណត់បញ្ហា និង ការលើកឡើងនូវដំណោះស្រាយ

*ថ្ងៃពុធ ទី ១៨ ខែធ្នូ ឆ្នាំ ២០១៩*

---

ការត្រួតពិនិត្យផែនការសាលាឱ្យបានគ្រប់ជ្រុងជ្រោយ (CSPR) គឺជាដំណើរការសហការគ្នា ដែលនឹងវាយតម្លៃ ការចុះឈ្មោះចូលរៀន អាគារសិក្សា និង ការផ្ដល់កម្មវិធីអប់រំ របស់សាលាក្នុងតំបន់ របស់ក្រសួង ដើម្បីជួយយើងក្នុងការរៀបចំផែនការនាពេលអនាគត តាមវិធីមួយដែលធានាថាសិស្សរបស់យើងអាចទទួលបានសាលារៀនល្អដែលនៅជិតកន្លែងដែលពួកគេរស់នៅ។

---

**<u>គោលបំណងនៃអង្គប្រជុំ៖</u>**

- កែលម្អបញ្ហាដែលទាក់ទងនឹង ការចុះឈ្មោះចូលរៀន អាគារសិក្សា និង ការផ្ដល់កម្មវិធីអប់រំ
- លើកឡើងនូវដំណោះស្រាយលើរាល់បញ្ហាដែលគេបានរកឃើញ ជាមួយនឹងគោលបំណងនៃការបង្កើតគំនិតដើម្បីណែនាំពីជម្រើសនាពេលអនាគត

**<u>ចំណុចខំខាន់ៗនៃ អង្គប្រជុំលើកទី ២</u>**

| កម្រិតនៃកិច្ចព្រមព្រៀងលើមាត្រដ្ឋានពី ១ ដល់ ៥ (១ មិនយល់ស្របទាំងស្រុង - ៥ យល់ស្របទាំងស្រុង) | | | | |
|---|---|---|---|---|
| | វគ្គនេះជួយខ្ញុំឱ្យយល់កាន់តែច្បាស់អំពីដំណើរការរបស់ CSPR ។ | ខ្ញុំមានអារម្មណ៍ធម្មតាក្នុងការបញ្ចេញយោបល់របស់ខ្ញុំនៅក្នុងអង្គប្រជុំ | អង្គប្រជុំនេះគឺជាការចំណាយពេលវេលាមានប្រយោជន៍របស់ខ្ញុំ | ខ្ញុំមានអារម្មណ៍ថាគេផ្ដល់តម្លៃដល់ វគ្គមាន និង មតិយោបល់របស់ខ្ញុំ នៅក្នុងដំណើរការរបស់ CSPR |
| តំបន់សិក្សាទី ១ | ៣,១៩ | ៣,៧៧ | ៣,១០ | ៣,៣២ |
| តំបន់សិក្សាទី ២ | ៣,៦៩ | ៤,០០ | ៤,០៨ | ៣,៩២ |
| តំបន់សិក្សាទី ៣ | ៤,៣៣ | ៤,៣៣ | ៤,៥០ | ៤,៥០ |
| តំបន់សិក្សាទាំងអស់ | ៣,៤៦ | ៣,៩០ | ៣,៥៣ | ៣,៦២ |

**ការផ្ដល់មតិយោបល់ដែលគេបានរួមបញ្ចូល៖**

- មានអារម្មណ៍ថាបន្ទាន់ពេក គ្មានពេលគ្រប់គ្រាន់ជាមួយនឹងទិន្នន័យ
- តើមតិយោបល់របស់យើងមានសារៈសំខាន់ដែរឬទេ ឬ ៤៤០ ធ្វើការសម្រេចចិត្តទាំងអស់
- មានការសង្ស័យអំពីការដែលយើងទទួលការគាំទ្រពី BOE (គណៈកម្មការអប់រំ)

**អ្វីដែលយើងបានស្វែងយល់មកដល់ពេលនេះ៖**

- **មានព័ត៌មានជាច្រើនដែលគ្រប់គ្នាត្រូវទទួលយក**
- **យើងត្រូវការពេលវេលាបន្ថែមទៀត៖**
  - រវាង អង្គប្រជុំក្រុមអ្នកផ្ដល់យោបល់ និង អង្គប្រជុំគណៈកម្មការរៀបចំផែនការ
  - រវាងអង្គប្រជុំគណៈកម្មការរៀបចំផែនការ
  - ជាមួយអគ្គនាយក
  - សម្រាប់ការបកប្រែ
- **យើងត្រូវការពន្យាពេល**
  - ការចូលរួមរបស់សហគមន៍
  - ការចូលរួមរបស់នាយកសាលា
  - ការចូលរួមរបស់សិស្សានុសិស្ស

ជាលទ្ធផល គេបានពន្យាពេលកំណត់ ដើម្បីផ្ដល់ពេលវេលាដែលពួកគេត្រូវការ៖

| កាលបរិច្ឆេទពីដំបូង | កាលបរិច្ឆេទដែលបានស្នើសុំ | យោបល់ |
|---|---|---|
| **គណៈកម្មការរៀបចំផែនការ** | | |
| ៨ មករា | ២២ មករា | ប្ដូរសម្រាប់ពេលវេលាដំណើរការ |
| ៥ កុម្ភៈ | ៥ កុម្ភៈ | ដូចបានកំណត់* |
| ១៩ កុម្ភៈ | | លុបចោលពីកាលវិភាគ |
| ១៨ មីនា | ១៨ មីនា | ដូចបានកំណត់ |
| | ១ មេសា | បន្ថែមក្នុងកាលវិភាគ |
| | ១០ មេសា | បន្ថែមក្នុងកាលវិភាគ |
| **វេទិកាសុំមតិយោបល់ពីសហគមន៍** | | |
| ២២ មករា | ៤ មីនា | រុញវេទិកាទីមួយមកក្រោយ ហើយប្ដូរវេទិកាទីពីរទៅខែមេសា |
| ៤ មីនា | ២២ មេសា | |

*ប្ដូរកាលវិភាគនេះមកវិញ ដោយយោងតាមយោបល់របស់នាយកសាលានៅក្នុងអង្គប្រជុំ

**<u>ជម្រើស - ករណីដែលត្រូវសិក្សា</u>**

Tyler Vick មកពី FLO ណែនាំដល់សមាជិកគណៈកម្មការរៀបចំផែនការ ពីករណីដែលត្រូវសិក្សាពីក្រសួងអប់រំមួយផ្សេងទៀត។

**<u>ការកំណត់បញ្ហាសំខាន់</u>**

អ៊ីងក្រ្គីដ ប៊ុឆើរ មកពី BLOOM Planning បានស្នើសុំឱ្យបុគ្គលម្នាក់ៗបំបែកទៅតាមក្រុមរបស់ខ្លួន ដែលគេបានរៀបចំទៅតាមតួនាទី (នាយកសាលា គ្រូបង្រៀន ឪពុកម្តាយ) និង ឆ្លើយតបទៅនឹងបញ្ហា និង ចំណុចសំខាន់ៗ ដែលគេបានចែករំលែក។ បញ្ហាទាំងនោះរួមមាន៖

**បញ្ហាដំបូងដែលគេបានកំណត់ សម្រាប់តំបន់សិក្សាទី ២**

- **ការមិនសូវប្រើប្រាស់អាគារ និង ការធ្លាក់ចុះនៃការចុះឈ្មោះចូលរៀន**
  - សាលា Cramp, Munoz-Marin និងសាលា Sheppard មានចំនួនក្រោម ៧0%
  - សាលា Elkin, Potter-Thomas និងសាលា Willard បានឃើញការធ្លាក់ចុះនៃការចុះឈ្មោះចូលរៀនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ
- ការរៀបចំកម្រិតថ្នាក់ធ្វើឱ្យមានការលំបាកដល់ការផ្លាស់ប្តូរ
  - មត្តេយ្យ ដល់ថ្នាក់ទី ៤ (សាលា Elkin, Sheppard, និងសាលា Willard) មត្តេយ្យ ដល់ថ្នាក់ទី ៥ (Cramp) និងសាលា មត្តេយ្យ ដល់ថ្នាក់ទី ៨ (សាលា De Burgos, Munoz-Marin, និងសាលា Potter-Thomas)

**ចំណុចបន្ថែមទៀតដែលត្រូវយកចិត្តទុក**

- ច្រករបៀង ដែលអាចដើរបាន និង មានសុវត្ថិភាព
- ផលប៉ះពាល់នៃ ការធ្វើអន្តោប្រវេសន៍ និង ការផ្លាស់ប្តូរទីកន្លែង របស់សិស្ស លើការចុះឈ្មោះចូលរៀន
- គ្រួសារជ្រើសរើសសាលាឆាទ័រនៅក្នុងតំបន់
- ការយល់ឃើញអំពីសាលា (គុណភាព ស្ថានភាព កម្មវិធី)

នៅពេលគេចែករំលែកព័ត៌មាន ក្រុមនានាមានប្រតិកម្មទៅនឹងបញ្ហាទាំងនោះ ដោយផ្ទៀងផ្ទាត់មើលថាតើបញ្ហាណាដែលសំខាន់សម្រាប់ពួកគាត់ និង កត់សម្គាល់ថាតើមានបញ្ហាណាមួយដែល បាត់ ឬ ខុស។ ពួកគេបានពិភាក្សាពីបញ្ហានីមួយៗដោយឡែកពីគ្នា និង លើកឡើងពីការព្រួយបារម្ភបន្ថែមទៀតរហូតមកដល់ពេលនេះ។

**<u>លើកឡើងពីដំណោះស្រាយ</u>**

ក្រុមអ្នកសម្របសម្រួលរបស់ CSPR បានចែករំលែកបញ្ជីនៃដំណោះស្រាយដែលអាចធ្វើបាន និង បានគូសបញ្ជាក់ថាដំណោះស្រាយផ្សេងទៀតអាចធ្វើទៅបាន ប៉ុន្តែបញ្ជីនេះអាចជាការចាប់ផ្តើមការសន្ទនា។

បំបែកក្រុម បន្ទាប់មកបានបន្តការសន្ទនាពីមុនរបស់ពួកគេ ហើយប្តូរការផ្តោតអារម្មណ៍ទៅរកអ្វីដែលអាចជាដំណោះស្រាយ។

- **សំណង់ បន្ថែម/ថ្មី៖** ការសាងសង់អាគារថ្មី ឬការជួសជុលអាគារដែលមានស្រាប់ ដើម្បីបំពេញតម្រូវការនាពេលអនាគត។
- **ការផ្លាស់ប្តូរព្រំដែន៖** ការតម្រែតម្រង់ព្រំដែនដើម្បីសម្រួលដល់ការផ្លាស់ប្តូរនៃ ប្រជាជន និង សហគមន៍ នៅទូទាំងទីក្រុងរបស់យើង។

- **ការបិទ៖** ការលុបបំបាត់ កម្មវិធីសិក្សា និង/ឬ អាគារសាលា។
- **ការប្រើកន្លែងចូលគ្នា៖** ចែករំលែកកន្លែងទំនេរសម្រាប់ ការអប់រំ ឬ មុខងាររដ្ឋបាល ដែលសមស្រប។
- **ការរួមបញ្ចូលគ្នា៖** ការរៀបចំឡើងវិញនៃចំនួនសិស្ស ដើម្បីបម្រើសេចក្តីត្រូវការនៃការអប់រំរបស់សិស្សឱ្យបានប្រសើរជាងមុន។
- **ការផ្លាស់ប្តូរកម្រិតថ្នាក់៖** ការបន្ថែម ឬ ការកាត់បន្ថយ កម្រិតថ្នាក់។
- **ការផ្លាស់ប្តូរច្បាប់៖** ការផ្លាស់ប្តូរច្បាប់របស់ក្រសួង និង នីតិវិធីរដ្ឋបាល។
- **ការផ្លាស់ទីកន្លែង៖** ការផ្លាស់ប្តូរកម្មវិធីអប់រំទៅកន្លែងផ្សេង។
- **ការចម្លង៖** ការចម្លងកម្មវិធីសិក្សាដែលមានគុណភាពខ្ពស់។
- **ដំណើរនៃការផ្លាស់ប្តូរ៖** បង្កើតដំណើរនៃការផ្លាស់ប្តូរដោយគិតគូរយ៉ាងហ្មត់ចត់សម្រាប់សិស្សនៅ បឋមសិក្សា និង អនុវិទ្យាល័យ។

នៅចុងបញ្ចប់នៃការសន្ទនា គេសុំឱ្យសមាជិកម្នាក់មកពីក្រុមនីមួយៗ ចែករំលែកនូវ គំនិត/ដំណោះស្រាយ សំខាន់ៗមួយចំនួនដែលគេបានចែករំលែកនៅក្នុងការសន្ទនារបស់ពួកគេ។

**<u>ជំហានបន្ទាប់ និង ការបញ្ចប់អង្គប្រជុំ</u>**

អ្នកវិភាគរបស់ FLO បានប្រាប់ថា ពួកគេនឹងទទួលយកអ្វីដែលអាចជាដំណោះស្រាយដែលគេបានលើកឡើង ក៏ដូចជាការផ្តល់មតិយោបល់លើបញ្ហាសំខាន់ៗ ហើយប្រើព័ត៌មានទាំងនេះដើម្បីបង្កើតជម្រើសលើកទីមួយ សម្រាបប់ឱ្យគណៈកម្មធិការរៀបចំផែនការប្រតិកម្មតប។

FLO បានសង្កត់ធ្ងន់ថា នឹងមានរយៈពេលពីរបីខែដើម្បីបង្កើតជម្រើស ហើយខែមករាគ្រាន់តែជាជំហានដំបូងនៃទិសដៅនេះ។

**ការរំឭក - កាលវិភាគថ្មីនៃអង្គប្រជុំតំបន់សិក្សា (SA1 គូសបញ្ជាក់ពណ៌ទឹកក្រូច)៖**

| ពេលវេលា | តំបន់សិក្សាទី ១ | តំបន់សិក្សាទី ២ | តំបន់សិក្សាទី ៣ |
|---|---|---|---|
| មករា | ២១ មករា | ២២ មករា | ២៣ មករា |
| កុម្ភៈ | ៤ កុម្ភៈ | ៥ កុម្ភៈ | ៦ កុម្ភៈ |
| មីនា | ៣ មីនា – ប្រជុំសុំមតិយោបល់ពីសាធារណៈជន | ៤ មីនា – ប្រជុំសុំមតិយោបល់ពីសាធារណៈជន | ៥ មីនា – ប្រជុំសុំមតិយោបល់ពីសាធារណៈជន |
| | ១៧ មីនា | ១៨ មីនា | ១៩ មីនា |
| មេសា | ៣១ មីនា | ១ មេសា | ២ មេសា |
| | ២១ មេសា – ប្រជុំសុំមតិយោបល់ពីសាធារណៈជន | ២២ មេសា – ប្រជុំសុំមតិយោបល់ពីសាធារណៈជន | ២៣ មេសា – ប្រជុំសុំមតិយោបល់ពីសាធារណៈជន |
| ឧសភា | ១៩ ឧសភា | ២០ ឧសភា | ២១ ឧសភា |
| មិថុនា | នាំយកសំណូមពរទៅឱ្យគណៈកម្មការអប់រំ | | |